វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
The NGO Forum on Cambodia
ធ្វើការរួមគ្នាដើម្បីភាពប្រសើរឡើង





ខែកញ្ញា ឆ្នាំ ២០០៨, លេខ: ០១

# ថវិកាជាតិឆ្នាំ ២០០៩ គប្បីគាំទ្រដល់កសិករ

## សេចក្តីផ្តើម

ការផ្សារភ្ជាប់ថវិកាជាតិខាងមុខនេះទៅនឹងក្របខ័ណ្ឌគោលនយោបាយដែលបានលើកឡើងនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ទំនងជាភារៈកិច្ចដ៏លំបាកបំផុតមួយដែលមន្ត្រីរដ្ឋាភិបាលនៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកំពុងជួបប្រទះនៅពេលនេះ។ ខណៈដែលតំណាងមកពីក្រសួងពាក់ព័ន្ធនានា និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកំពុងចរចាវិភាជន៍ថវិកាសម្រាប់សេចក្តីព្រាងច្បាប់ថវិកាឆ្នាំ ២០០៩ របាយការណ៍សង្ខេបថវិកានេះពិនិត្យមើលៈ ១) អាទិភាពដែលត្រូវបានផ្សារភ្ជាប់ទៅនឹងវិស័យកសិកម្ម និងអភិវឌ្ឍន៍ជនបទនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ, ២) ការធ្វើវិភាជន៍ថវិកាទៅឱ្យវិស័យទាំងពីរនេះនៅក្នុងរយៈពេលបួនឆ្នាំកន្លងមក និង ៣) ចំណាយជាក់ស្តែងនៅក្នុងវិស័យទាំងពីរនេះ។

*"ភាពក្រីក្រមានកម្រិតខ្ពស់នៅតំបន់ជនបទ ជាពិសេស នៅតំបន់ដាច់ស្រយាល"*

*"ប្រជាជនកម្ពុជាជាង ៨៥ ភាគរយរស់នៅតំបន់ជនបទ "*
*(ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ ២០០៦-២០១០)*

របាយការណ៍សង្ខេបនេះនឹងបញ្ចប់ជាមួយនឹងការអំពាវនាវសុំឱ្យរាជរដ្ឋាភិបាលដែលគាំទ្រដោយដៃគូអភិវឌ្ឍន៍របស់ខ្លួន តម្រង់ទិសមូលនិធិសាធារណៈឱ្យបានកាន់តែច្រើនឡើងថែមទៀតនៅក្នុងច្បាប់ថវិកាជាតិឆ្នាំ ២០០៩ ដើម្បីជម្រុញវិស័យកសិកម្ម និង អភិវឌ្ឍន៍ជនបទ។

## គោលនយោបាយនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងកំណើនភាពសមស្របនៃគោលនយោបាយទាំងនេះពីឆ្នាំ ២០០៧មក

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (២០០៦-២០១០) ចែងយ៉ាងច្បាស់លាស់អំពីសារៈសំខាន់នៃវិស័យកសិកម្មដើម្បីកាត់បន្ថយភាពក្រីក្រៈ "***ការលើកស្ទួយវិស័យកសិកម្ម គឺជាកត្តាគន្លឹះសម្រាប់ការកាត់បន្ថយភាពក្រីក្រ ហើយក៏រួមចំណែកយ៉ាងច្រើននៅក្នុងកំណើនផលិតផលក្នុងស្រុកសរុប និងម៉ាក្រូសេដ្ឋកិច្ច។ ភាពក្រីក្រមានកម្រិតខ្ពស់នៅជនបទជាពិសេសនៅតំបន់ដាច់ស្រយាល។ ប្រជាជនកម្ពុជាជាង ៨៥ ភាគរយរស់នៅតំបន់ជនបទ ហើយជាង ៦០ ភាគរយរស់នៅដោយពឹងផ្អែកលើកសិកម្ម ព្រៃឈើ និងនេសាទ។ ៧៥ភាគរយនៃគ្រួសារក្រីក្រ គឺជាគ្រួសារដែលមានមេគ្រួសារជាកសិករ***"។

*ដោយសារតម្លៃអង្ករប្រភេទផ្សេងទៀតក៏បានឡើងថ្លៃពីរដងផងដែរ ផលចំណេញពីវិនិយោគសាធារណៈលើវិស័យកសិកម្មបានកើនឡើងយ៉ាងច្រើន។*

ពីខែឧសភា ឆ្នាំ ២០០៧ ដល់ ខែឧសភា ឆ្នាំ ២០០៨ តម្លៃអង្ករផ្កាខ្ញីពីខេត្តបាត់ដំបងបានឡើងថ្លៃ ១០៥ ភាគរយពី ១.៤៩១ រៀល ដល់ ៣.០៥៨ រៀលក្នុងមួយគីឡូក្រាម។ ដោយសារតម្លៃអង្ករប្រភេទផ្សេងទៀតក៏បានឡើងថ្លៃពីរដងផងដែរ ផលចំណេញពីវិនិយោគសាធារណៈលើវិស័យកសិកម្មបានកើនឡើងយ៉ាងច្រើន។ ថ្វីបើតម្លៃអង្ករបានធ្លាក់ចុះបន្តិចនៅក្នុងខែសីហាក្តី ក៏តម្លៃនេះទំនង

រូបភាពដោយ នៅ វណ្ណារិន

ជានឹងមិនត្រឡប់ទៅរកកម្រិតកាល ពីខែ ឧសភា ឆ្នាំ ២០០៧ ដែរ។

ហេតុនេះគ្រឿងលើកទឹកចិត្តវិនិយោគបានប្រែប្រួលជាអចិន្ត្រៃយ៍ដែលមានលក្ខណៈអំណោយផលចំពោះវិស័យកសិកម្ម និងការបង្កើនវិនិយោគសាធារណៈក្នុងឆ្នាំ ២០០៩ ជាលទ្ធផលនឹងនាំឱ្យមានការកែលម្អប្រព័ន្ធស្រោចស្រព លទ្ធភាពទទួលបានធាតុចូលកសិកម្មប្រកបដោយគុណភាពល្អ បរិក្ខារស្តុកទុក និងបរិក្ខារកែច្នៃ។ វិនិយោគទាំងនេះគឺសុទ្ធតែមានលក្ខណៈល្អសម្រាប់កិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ចនៃប្រទេសកម្ពុជា។

## ហិរញ្ញប្បទានវិនិយោគសាធារណៈលើវិស័យកសិកម្ម និងអភិវឌ្ឍន៍ជនបទ

*"... កង្វះការផ្សារភ្ជាប់រវាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និង ថវិកាជាតិ... នៅតែជាឧបករណ៍គោលនយោបាយសេដ្ឋកិច្ចសំខាន់បំផុតរបស់រាជរដ្ឋាភិបាល"*

នៅពេលគិតគូរដោះស្រាយការផ្តល់ហិរញ្ញប្បទានដើម្បីអនុវត្តគោលនយោបាយទាំងនេះ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិគោរពតាមភាពសមហេតុផលនៃការគូសបញ្ជាក់ថា ដោយសារការកាត់បន្ថយភាពក្រីក្រគឺជាគោលដៅ នោះ ៦០ ភាគរយ នៃវិភាជន៍ថវិកានឹងត្រូវបានប្រើប្រាស់ដើម្បីជាផលប្រយោជន៍នៃតំបន់ជនបទ។ តារាង ៥.២ នៃផែនការយុទ្ធសាស្ត្រដែលលើកឡើងពីការធ្វើវិភាជន៍តាមវិស័យ កំណត់កិច្ចអភិវឌ្ឍន៍ជនបទ និងវិស័យកសិកម្មថា មានសារៈសំខាន់ក្រៃលែងដើម្បីការខិតខំសម្រេចបានគោលដៅខាងលើនេះ។ ប្រភពមូលនិធិសម្រាប់ចំណាយសាធារណៈនេះគឺទទួលបានមកពីចំណូលរដ្ឋាភិបាល និងជំនួយអភិវឌ្ឍន៍ពីដៃគូអភិវឌ្ឍន៍។

ក្នុងបរិបទកម្ពុជាដែលនៅក្នុងនោះ ព័ត៌មានសាធារណៈទាក់ទិននឹងការគ្រប់គ្រងធនធានសាធារណៈនៅមានកម្រិត ប្រភពព័ត៌មានសំខាន់ៗ គឺ: ១) ច្បាប់ថវិកាជាតិ ២) កម្មវិធីវិនិយោគសាធារណៈ ៣) ច្បាប់ទូទាត់ថវិកា ៤) តារាងប្រតិបត្តិការហិរញ្ញវត្ថុ និង ៥) ទិន្នន័យជំនួយអភិវឌ្ឍន៍ពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ តារាងនៅក្នុងឧបសម្ព័ន្ធ ២ អធិប្បាយដោយសង្ខេបនូវខ្លឹមសារនៃប្រភពទាំងប្រាំនេះ និង វាយតម្លៃអត្ថប្រយោជន៍នៃប្រភពទាំងនេះសម្រាប់ការឃ្លាំមើលចំណាយសាធារណៈ។

## ថវិកាជាតិ: ចំណាយចរន្ត

រូបទី ១ បង្ហាញថានៅពេលដែលការធ្វើវិភាជន៍ថវិកាត្រូវបានកែតម្រូវតាមអតិផរណា គេពុំឃើញមាននិន្នាការច្បាស់លាស់ឆ្ពោះទៅកាន់ការធ្វើវិភាជន៍ថវិកាកាន់តែខ្ពស់សម្រាប់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងអភិវឌ្ឍន៍ជនបទទេ។ រូបនេះក៏បង្ហាញផងដែរថាថវិកាចរន្តសម្រាប់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបានកាត់បន្ថយនៅក្នុងរយៈពេលពីរឆ្នាំចុងក្រោយនេះ។ មូលហេតុសំខាន់នៃការកាត់បន្ថយនេះ គឺកង្វះខាតការផ្សារភ្ជាប់រវាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិទៅនឹងថវិកាជាតិដែលនៅតែជាឧបករណ៍គោលនយោបាយសេដ្ឋកិច្ចដ៏សំខាន់បំផុតរបស់រដ្ឋាភិបាល។ មូលហេតុមួយទៀត គឺអតិផរណាខ្ពស់ដែលគេមិនបានរំពឹងទុកជាមុនដែលបានកើនឡើងនៅក្នុងឆមាសទីពីរនៃឆ្នាំ ២០០៧ និងដែលបានបន្តចូលមកដល់ឆ្នាំ ២០០៨។ ថ្វីបើតម្លៃអង្ករ និងប្រេងចាប់ផ្តើមធ្លាក់ចុះក្នុងខែសីហាក្តីក៏តម្លៃទាំងនេះទំនងជានឹងនៅតែខ្ពស់។

**រូបទី ១: ថវិកាចរន្តគិតជាលានដុល្លារអាមេរិក, គិតតាមថ្លៃឆ្នាំ ២០០៧**




ជាទូទៅ ការអនុវត្តន៏ថវិកាចរន្តគឺល្អ និង មិនមានទាបជាង៩០ភាគរយឡើយក្នុងឆ្នាំ ២០០៥, ២០០៦, និង២០០៧។ ក្នុងឆ្នាំ ២០០៧ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានចាយ ៩៧ ភាគរយនៃថវិកាចរន្តរបស់ខ្លួន ខណៈដែលក្រសួងអភិវឌ្ឍន៏ជនបទបានចាយ ៩៣ ភាគរយនៃថវិកាចរន្តរបស់ខ្លួន។ ចំណុចមួយដែលគួរឱ្យកត់សម្គាល់គឺថាស្ថាប័នរដ្ឋាភិបាលផ្សេងទៀតបានចាយលើសថវិកាចរន្តរបស់ខ្លួនរាល់ឆ្នាំនៅក្នុងរយៈពេលបួនឆ្នាំចុងក្រោយនេះ។ ទីស្ដីការគណៈរដ្ឋមន្ត្រីបានចាយ ៤៣ ភាគរយលើសវិភាជន៏ថវិកាចរន្តរបស់ខ្លួនក្នុងឆ្នាំ ២០០៤ និង ៩១ ភាគរយលើសវិភាជន៏ថវិកាចរន្តដែលបានគ្រោងក្នុងច្បាប់ថវិកាឆ្នាំ ២០០៧។

## ថវិកាជាតិ: ចំណាយមូលធន

ខណៈដែលថវិកាចរន្តត្រូវបានធ្វើហិរញ្ញប្បទានភាគច្រើនពីចំណូលក្នុងស្រុក ថវិកាមូលធនត្រូវបានធ្វើហិរញ្ញប្បទានភាគច្រើនពីជំនួយបរទេស។ រូបទី ២ បង្ហាញថាពុំមាននិន្នាការច្បាស់លាស់ទេ ឆ្ពោះទៅកាន់ការធ្វើវិភាជន៏ថវិកាមូលធនកាន់តែខ្ពស់ឡើងសម្រាប់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ក្រសួងអភិវឌ្ឍន៏ជនបទ។ ផ្អែកលើរូបនេះ គេឃើញច្បាស់ថា នៅពេលកែតម្រូវតាមអតិផរណា ថវិកាមូលធនឆ្នាំ ២០០៨ សម្រាប់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមពិតទៅបានត្រឡប់ទៅរកកម្រិតឆ្នាំ ២០០៥ វិញ។ ថវិកាមូលធនដែលត្រូវបានវិភាជសម្រាប់ក្រសួងអភិវឌ្ឍន៏ជនបទមានស្ថេរភាពសម្រាប់ឆ្នាំ ២០០៤–២០០៧ ហើយមានការធ្លាក់ចុះច្រើនក្នុងច្បាប់ថវិកាឆ្នាំ ២០០៨។

**រូបទី ២: ថវិកាមូលធនគិតជាលានដុល្លារអាមេរិក, គិតតាមថ្លៃ ឆ្នាំ ២០០៧**



ក្រៅពីកង្វះខាតនៃការបង្កើនថវិការបស់ខ្លួន ការអនុវត្តន៍គម្រោងមូលធននានាដោយក្រសួងទាំងពីរ គឺមានបញ្ហា។ ដូចមានបង្ហាញជូននៅក្នុង**រូបទី ៣** ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ក្រសួងអភិវឌ្ឍន៍ជនបទ មានលទ្ធភាពចាយតាមលំដាប់រៀង១ខ្លួនបានត្រឹមតែ ៥០ ភាគរយ និង ៧៤ ភាគរយប៉ុណ្ណោះនៃថវិកាមូលធនរបស់ខ្លួនក្នុងឆ្នាំ២០០៧។ ដោយសារសេចក្តីត្រូវការវិនិយោគសាធារណៈនៅតំបន់ជនបទគឺខ្ពស់ រាជរដ្ឋាភិបាល និង ដៃគូអភិវឌ្ឍន៍របស់ខ្លួនគប្បីដោះស្រាយជាបន្ទាន់នូវមូលហេតុនៃការចាយមិនគ្រប់នេះ។

គេចាំបាច់ត្រូវកត់សម្គាល់ថាពុំមានទិន្នន័យអំពីចំណាយមូលធនដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និងក្រសួងអភិវឌ្ឍន៍ជនបទទេសម្រាប់ឆ្នាំ ២០០៤ និង ២០០៥។ សម្រាប់ឆ្នាំ ២០០៦ និង ២០០៧ ការគណនាការអនុវត្តថវិកាមូលធន គឺផ្អែកលើទិន្នន័យអនុវត្តន៍ដែលបានចេញផ្សាយក្នុងច្បាប់ថវិកាជាតិឆ្នាំ ២០០៧ និង ឆ្នាំ ២០០៨។ ថ្វីបើទិន្នន័យទាំងនេះគឺជាទិន្នន័យបឋមក្តីក៏រាជរាជរដ្ឋាភិបាលនៅមិនទាន់បានបញ្ចេញទិន្នន័យណាដែលបង្ហាញការអនុវត្តខុសគ្នាពីទិន្នន័យដែលត្រូវបានបង្ហាញជូនក្នុងរូបទី ៣ នេះទេ។

### រូបទី ៣: ការអនុវត្តន៍ថវិកាមូលធន




*"...២០០៨ ថវិកាមូលធនឆ្នាំ២០០៨សម្រាប ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាម ពិតបានត្រឡប់ទៅរកកម្រិតឆ្នាំ២០០៥ វិញ។"*

*"ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងអភិវឌ្ឍន៍ជនបទមានលទ្ធភាពចាយ តាមលំដាប់រៀង១ខ្លួនបានត្រឹមតែ៥០ ភាគរយ និង ៧៤ ភាគរយ ប៉ុណ្ណោះនៃថវិកាមូលធន របស់ខ្លួនក្នុងឆ្នាំ ២០០៧។"*

## សេចក្តីសន្និដ្ឋាន និង អនុសាសន៍

នៅក្នុងរយៈពេលប្រាំឆ្នាំចុងក្រោយនេះរាជរដ្ឋាភិបាលនៅមិនទាន់អាចប្រែក្លាយការប្តេជ្ញាចិត្តដ៏មុតមាំខាងគោលនយោបាយរបស់ខ្លួនចំពោះកិច្ចអភិវឌ្ឍន៍ជនបទឱ្យក្លាយទៅជាគម្រោងអភិវឌ្ឍន៍ជាក់ស្តែង។ ទិន្នន័យស្តីពីការធ្វើវិភាជន៍នៅក្នុងច្បាប់ថវិកាជាតិ និងទិន្នន័យតិចតួចស្តីពីការអនុវត្តថវិកាបង្ហាញថា វិនិយោគសាធារណៈមិនបានកំណត់កិច្ចអភិវឌ្ឍន៍ជនបទជាអាទិភាពទេដែលពន្យល់យ៉ាងហោចណាស់មួយផ្នែកដែរនូវល្បឿនជាមធ្យមនៃការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។

*ច្បាប់ថវិកាឆ្នាំ ២០០៩ គឺជាឱកាសមួយ សម្រាប់រាជរដ្ឋាភិបាលកម្ពុជាធ្វើការចាប់ផ្តើម ជាក់ស្តែងដើម្បីកែប្រែនិន្នាការនៃវិនិយោគ មិនគ្រប់គ្រាន់នៅតំបន់ជនបទ និង ព្យាយាម ឆ្ពោះទៅកាន់គោលដៅដែលបានប្រកាសដោយ រដ្ឋមន្ត្រីក្រសួង កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ កាលពីថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០០៨ ថា: "ប្រទេសកម្ពុជានឹងអាចផលិត ស្រូវបានប្រាំបីលានតោនសម្រាប់ការនាំចេញ រៀងរាល់ឆ្នាំ នៅឆ្នាំ ២០១៥។"*

**ដល់ពេលហើយ** ដែលរាជរដ្ឋាភិបាល ដោយមានការជួយគាំទ្រពីដៃគូអភិវឌ្ឍន៍របស់ខ្លួនត្រូវផ្តាច់ខ្លួនពីនិន្នាការនេះ និងវិនិយោគមូលនិធិសាធារណៈកាន់តែច្រើនឡើងទៅលើការអភិវឌ្ឍតំបន់ជនបទដែលផ្តល់អត្ថប្រយោជន៍ច្រើនបំផុតជូនដល់ប្រជាជនក្រីក្រ។ សម្រាប់អ្នកធ្វើគោលនយោបាយ និងសេចក្តីសម្រេចចិត្តនៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គណៈរដ្ឋមន្ត្រី និងដៃគូអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលគប្បីមើលឃើញយ៉ាងច្បាស់ថា តម្លៃខ្ពស់នៃអង្ករបង្កើនផលចំណេញសេដ្ឋកិច្ចពីវិនិយោគលើវិស័យកសិកម្ម និងអាចស្រោចស្រង់ប្រជាជនក្រីក្រជាច្រើននៅតាមតំបន់ជនបទឱ្យចាកផុតពីភាពក្រីក្រ។ ច្បាប់ថវិកាឆ្នាំ ២០០៩ គឺជាឱកាសមួយសម្រាប់រាជរដ្ឋាភិបាលកម្ពុជាធ្វើការចាប់ផ្ដើមជាក់ស្ដែង ដើម្បីកែប្រែនិន្នាការនៃវិនិយោគមិនគ្រប់គ្រាន់នៅតំបន់ជនបទ និងព្យាយាមឆ្ពោះទៅកាន់គោលដៅដែលបានប្រកាសដោយរដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ កាលពីថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០០៨ ថាៈ "*ប្រទេសកម្ពុជានឹងអាចផលិតស្រូវបានប្រាំបីលានតោនសម្រាប់ការនាំចេញរៀងរាល់ឆ្នាំនៅឆ្នាំ២០១៥*"[១] ។ ការដាក់សំណើសុំកម្មវិធីជំនួយស្បៀងអាហារដែលមានទឹកប្រាក់ចំនួន ៣៨ លានដុល្លារអាមេរិក ជូនធនាគារអភិវឌ្ឍន៍អាស៊ី[២] ដែលរួមមានសមាសភាគមួយដើម្បីបង្កើនផលិតកម្មស្បៀងអាហារក្នុងស្រុកគឺជាការចាប់ផ្ដើមគួរឱ្យសង្ឃឹមមួយ ហើយកម្មវិធីច្រើនថែមទៀតដែលលើកស្ទួយផលិតកម្មខ្នាតតូចចាំបាច់គួរត្រូវផ្ដួចផ្ដើម។

**វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា សូមអំពាវនាវដល់អ្នកធ្វើគោលនយោបាយ និងសេចក្ដីសម្រេចចិត្តទាំងអស់សូមផ្លាស់ប្តូរនិន្នាការកន្លងមក និងខិតខំធានាឱ្យបានប្រាកដថាច្បាប់ថវិកាជាតិឆ្នាំ ២០០៩ ពិតជាគាំទ្រកសិករតូចតាចឱ្យបានច្បាស់លាស់។**

***<u>សេចក្ដីសង្ខេប</u>***

- **តំបន់ជនបទកម្ពុជាមិនមែនក្រទេ ប៉ុន្តែ ប្រជាជនកម្ពុជាដែលរស់នៅជនបទទេគឺក្រ។**
- **វិនិយោគសាធារណៈលើការអភិវឌ្ឍន៍ជនបទ មានលក្ខណៈទាបក្នុងរយៈពេលកន្លងមក។**
- **តម្លៃស្រូវខ្ពស់ បានបង្កើនចំណេញពីវិនិយោគសាធារណៈលើវិស័យកសិកម្ម។**

- **ដល់ពេលហើយសម្រាប់ការផ្លាស់ប្តូរៈ ថវិកាជាតិឆ្នាំ ២០០៩ គប្បីគាំទ្រកសិករឱ្យបានច្បាស់លាស់។**

***<u>ដើម្បីព័ត៌មានបន្ថែម សូមទាក់ទងៈ</u>***

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្ដីពីកម្ពុជា

គម្រោងថវិកាជាតិ

ទូរស័ព្ទៈ (៨៥៥) ២៣ ២១៤ ៤២៩ លេខបន្ត ១០៧

អ៊ីម៉ែលៈ ngoforum@ngoforum.org.kh

គេហទំព័រៈ www.ngoforum.org.kh

*ក្នុងស្មារតីជួយលើកកំពស់តម្លាភាពអោយកាន់តែច្រើន វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជាសូមសំណូមពរដល់អ្នកអានដែលមានឯកសារ និង/ឬ ព័ត៌មានដែលគួរតែត្រូវផ្សព្វផ្សាយទៅកាន់សាធារណៈជនកម្ពុជាអោយបានដឹង សូមធ្វើការទាក់ទងមកយើងខ្ញុំតាមព័ត៌មានខាងលើ។*

[១] សារព័ត៌មាន ស៊ីនហួ ថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០០៨។

[២] កាសែតខែមបូឌៀដេលី ថ្ងៃទី ៤ ខែ កញ្ញា ឆ្នាំ ២០០៨។

## ឧបសម្ព័ន្ធ ១: ទិន្នន័យដែលបានប្រើ

| | ២០០៣ | ២០០៤ | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ |
|---|---|---|---|---|---|---|
| សន្ទស្សន៍តម្លៃទំនិញប្រើប្រាស់ | ១០០.០ | ១០៥.៤ | ១១០.៦ | ១១៥.៨ | ១៣៤.៧ | ១៦៥.៧ |
| អតិផរណា តាមវិទ្យាស្ថានជាតិស្ថិតិ | | ៥.៤% | ៥.០% | ៤.៧% | ១៦.៣% | ២៣.០*% |
| អត្រាប្តូរប្រាក់ (រៀលក្នុងមួយដុល្លារអាមេរិក)** | ៣.៩៧៩ | ៤.០១៩ | ៤.០៩៧ | ៤.១០៧ | ៤.០៧៣ | ៤.១០០ |

* ព្យាករណ៍ដោយអង្គភាពពិសេសអ្នកសេដ្ឋកិច្ច របាយការណ៍ប្រចាំប្រទេសកម្ពុជា ខែ សីហា ឆ្នាំ ២០០៨។

**អត្រាប្តូរប្រាក់ធនាគារជាតិនៃកម្ពុជា (រៀល/ដុល្លារអាមេរិក), សំរាប់ឆ្នាំ ២០០៨ អត្រាប្តូប្រាក់យោងតាមអត្រាដែលប្រើនៅក្នុងច្បាប់ថវិកាឆ្នាំ ២០០៨

### វិភាជន៍ថវិកាចរន្ត (លានដុល្លារអាមេរិក)

| | ២០០៤ | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ |
|---|---|---|---|---|---|
| ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ១១.៩ | ១២.២ | ១៣.៨ | ១៤.៦ | ១៦.២ |
| ក្រសួងអភិវឌ្ឍន៍ជនបទ | ៥.៩ | ៦.០ | ៨.១ | ៩.១ | ១១.៧ |

គណនាចេញពីច្បាប់ថវិកាជាតិ, រាជរដ្ឋាភិបាលកម្ពុជា

### ចំណាយចរន្តជាក់ស្តែង (លានដុល្លារអាមេរិក)

| | ២០០៤ | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ |
|---|---|---|---|---|---|
| ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ៩.៦ | ១១.៥ | ១៣.៦ | ១៤.២ | - |
| ក្រសួងអភិវឌ្ឍន៍ជនបទ | ៤.១ | ៥.៤ | ៧.៣ | ៨.៥ | - |

គណនាចេញពីរបាយការណ៍តារាងប្រតិបត្តិការហិរញ្ញវត្ថុ, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

### វិភាជន៍ថវិកាមូលធន (លានដុល្លារអាមេរិក)

| | ២០០៤ | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ |
|---|---|---|---|---|---|
| ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ៤៤.១ | ៣៣.៣ | ២៦.៥ | ៣៦.២ | ៥១.៥ |
| ក្រសួងអភិវឌ្ឍន៍ជនបទ | ១៤.២ | ១៩.៥ | ១៥.៣ | ២០.៤ | ១៧.៦ |

គណនាចេញពីច្បាប់ថវិកាជាតិ, រាជរដ្ឋាភិបាលកម្ពុជា

### ចំណាយមូលធនជាក់ស្តែង (លានដុល្លារអាមេរិក)

| | ២០០៤ | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ |
|---|---|---|---|---|---|
| ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | | | ២៣.១ | ១៨.១ | |
| ក្រសួងអភិវឌ្ឍន៍ជនបទ | | | ១២.៤ | ១៥.១ | |

គណនាចេញពីច្បាប់ថវិកាជាតិ រាជរដ្ឋាភិបាលកម្ពុជា[៣]

[៣] តួលេខទាំងនេះត្រូវបានចាត់ថ្នាក់ជាទិន្នន័យបឋមដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប៉ុន្តែ តួលេខចុងក្រោយអំពីចំណាយមូលធន ជាក់ស្តែងគឺមិនទាន់មានទេ។ សម្រាប់ឆ្នាំ ២០០៤ និង ២០០៥ ពុំមានតួលេខអំពីចំណាយមូលធនទេនៅក្នុងច្បាប់ថវិកា ឬ ច្បាប់ទូទាត់ថវិកា។ សម្រាប់ឆ្នាំ ២០០៦ និង ២០០៧ ច្បាប់ទូទាត់ថវិកានៅមិនទាន់បានរៀបចំនៅឡើយ។

## ឧបសម្ព័ន្ធ ២: ប្រភពព័ត៌មានស្តីពីចំណាយសាធារណៈ

| ប្រភព | ខ្លឹមសារ / យោបល់ |
|---|---|
| ១) ច្បាប់ថវិកាជាតិ | ការធ្វើវិភាជន៍ថវិកាចរន្ត និងថវិកាមូលធនតាមក្រសួង ។<br>ការប៉ាន់ស្មានលើថវិកាចរន្ត និងថវិកាមូលធនតាមក្រសួងនៃឆ្នាំមុន ។<br>- កំណត់សម្គាល់ ១: រាជរដ្ឋាភិបាលកម្ពុជាមិនបញ្ចេញតួលេខចុងក្រោយអំពីចំណាយជាក់ស្តែងឱ្យបានទាន់ពេលវេលាគ្រប់គ្រាន់ដើម្បីផ្តល់ព័ត៌មានអំពីវដ្តថវិកា ។ |
| ២) កម្មវិធីវិនិយោគសាធារណៈ (PIP) | ការធ្វើវិភាជន៍គម្រោងកំពុងដំណើរការ (ជំនួយមូលធន និងបច្ចេកទេស) តាមក្រសួងដែលត្រូវបានផ្សារភ្ជាប់ទៅនឹងថវិកាជាតិតាំងពីឆ្នាំ ២០០៧ ។<br>បញ្ជីគម្រោងត្រៀមដែលមានអាទិភាពខ្ពស់ ។ |
| ៣) ច្បាប់ទូទាត់ថវិកា | ការពិនិត្យមើលជារួមលើចំណាយចរន្តប្រៀបធៀបនឹងចំណាយចរន្តដែលបានគ្រោងតាមក្រសួងក្នុងច្បាប់ថវិកា ។<br>ការពិនិត្យមើលជារួមលើចំណាយមូលធនប្រៀបធៀបនឹងចំណាយមូលធនដែលបានគ្រោងក្នុងច្បាប់ថវិកា ។<br>- កំណត់សម្គាល់ ១: តួលេខនៃចំណាយមូលធនដែលបានគ្រោងក្នុងច្បាប់ថវិកាមិនមែនសុទ្ធតែដូចគ្នានឹងតួលេខនៅក្នុងច្បាប់ទូទាត់ថវិកាទេ ។ ជួនកាល គេមិនឃើញមានព័ត៌មានស្តីពីចំណាយសម្រាប់ក្រសួងមួយចំនួន ។<br>- កំណត់សម្គាល់ ២: ក្នុងឆ្នាំខ្លះ គេមិនឃើញមានការបែងចែកចំណាត់ថ្នាក់ចំណាយមូលធនតាមក្រសួងឡើយ ។<br>- កំណត់សម្គាល់ ៣: ច្បាប់ទូទាត់ថវិកាសម្រាប់ឆ្នាំ ២០០៦ និង២០០៧ នៅមិនទាន់មាននៅឡើយ ។ |
| ៤) តារាងប្រតិបត្តិការហិរញ្ញវត្ថុ (TOFE) | ការពិនិត្យមើលជារួមលើចំណាយចរន្តប្រៀបធៀបនឹងចំណាយចរន្តដែលបានគ្រោងតាមក្រសួងក្នុងច្បាប់ថវិកា ។<br>ការពិនិត្យមើលជារួមលើចំណាយមូលធនប្រៀបធៀបនឹងចំណាយមូលធនដែលបានគ្រោងក្នុងច្បាប់ថវិកា ។<br>- កំណត់សម្គាល់ ១: តួលេខនៃចំណាយមូលធនដែលបានគ្រោងក្នុងច្បាប់ថវិកា មិនមែនសុទ្ធតែដូចគ្នានឹងតួលេខនៅក្នុងច្បាប់ថវិកាទេ ។ ជួនកាល គេមិនឃើញមានព័ត៌មានស្តីពីចំណាយសម្រាប់ក្រសួងមួយចំនួន ។ |
| ៥) មូលដ្ឋានទិន្នន័យជំនួយពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ការពិនិត្យមើលជារួមលើគម្រោង/កម្មវិធីពីដៃគូរអភិវឌ្ឍន៍ ។<br>- កំណត់សម្គាល់ ១: មូលដ្ឋានទិន្នន័យរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាពុំអាចប្រើជាមូលដ្ឋានសម្រាប់គោលបំណងឃ្លាំមើលដោយសារវាមិនត្រូវបានផ្សារភ្ជាប់ទៅនឹងថវិកាជាតិ ឬកម្មវិធីវិនិយោគសាធារណៈ ។ ថ្វីបើគម្រោងមួយចំនួនដែលត្រូវបានដាក់បញ្ចូលក្នុងប្រព័ន្ធទិន្នន័យរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាមានលក្ខណៈប្រហាក់ប្រហែលគ្នានឹងគម្រោងនៅក្នុងកម្មវិធីវិនិយោគសាធារណៈក្តី ក៏គេពុំឃើញមានប្រព័ន្ធផ្សារភ្ជាប់គ្នារវាងប្រព័ន្ធទិន្នន័យទាំងពីរ ហើយប្រព័ន្ធទាំងពីរនេះហាក់បីដូចជាដំណើរការជាប្រព័ន្ធពីរផ្សេងគ្នា ។ |

**ឯកសារបោះពុម្ពផ្សាយផ្សេងទៀតពីគម្រោងថវិកាជាតិនៃវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា:**

- ការវិភាគការអនុវត្តថវិកាឆ្នាំ ២០០៧ និងច្បាប់ថវិកាឆ្នាំ ២០០៨, ខែ មករា ឆ្នាំ ២០០៨។
- សៀវភៅណែនាំអំពីថវិកាជាតិ, ខែ វិច្ឆិកា ឆ្នាំ ២០០៧។
- ថវិកាជាតិកម្ពុជា និងកិច្ចអភិវឌ្ឍន៍: ប្រែក្លាយគោលនយោបាយឱ្យក្លាយទៅជាសកម្មភាព, កំណត់ជាអាទិភាពនូវថវិកាសំរាប់វិស័យអាទិភាពនានា!!, ការឃ្លាំមើលការអភិវឌ្ឍនៅកម្ពុជា (Cambodia Development Watch) ឆ្នាំទី ៣ ច្បាប់លេខ ១ ខែ កក្កដា ឆ្នាំ ២០០៧។
- "ថ្លៃចំណាយ ធនធាន និង ការធ្វើកម្មវិធី", ឯកសារជំហរអង្គការមិនមែនរដ្ឋាភិបាលស្តីពីការអភិវឌ្ឍកម្ពុជា ឆ្នាំ ២០០៦។ ខែ មិថុនា ឆ្នាំ ២០០៧ (ការឃ្លាំមើលសូចនាករតាមដានរួម និងការអនុវត្តផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ ឆ្នាំ ២០០៦-២០១០)
- បញ្ហាប្រឈមនានានៅក្នុងច្បាប់ថវិកាជាតិដើម្បីកាត់បន្ថយភាពក្រីក្រ, ការឃ្លាំមើលការអភិវឌ្ឍនៅកម្ពុជា (Cambodia Development Watch) ឆ្នាំទី ២ ច្បាប់លេខ ២ ខែ កក្កដា ឆ្នាំ ២០០៦។